ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃច័ន្ទ៨ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦សម្រាប់ឆ្នាំ២០២០ តាមប្រព័ន្ធ Bluejeans ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានសមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ខេត្ត និងអង្គការពាក់ព័ន្ធ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

- ការឆ្លើយតបប្រកបដោយចីរភាពឈានទៅបញ្ចប់អេដស៍ ជាគ្រោះគំរាមដល់សុខភាពសាធារណៈ ត្រឹមឆ្នាំ២០២៥។
- យុទ្ធនាការថ្នាក់ជាតិផ្សព្វផ្សាយ អប់រំបង្ការ មេរោគអេដស៍ និងជំងឺអេដស៍ ទទួលសេវាមេរោគអេដស៍ និងផ្សព្វផ្សាយសេវាមេរោគអេដស៍។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមតាមប្រព័ន្ធ Bluejeans នាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានកំណត់ ។

១. បទបង្ហាញការឆ្លើយតបប្រកបដោយចីរភាពឈានទៅបញ្ចប់អេដស៍ ជាគ្រោះគំរាមដល់សុខភាពសាធារណៈ ត្រឹមឆ្នាំ២០២៥ បង្ហាញដោយ ឯកឧត្តម អគ្គលេខាធិការ **ឈឹម ឃិនដារ៉េត**

២. ទំនាក់ទំនងអនឡាញ ( Communication on line ) បង្ហាញដោយអង្គការFHI360

៣.ផ្សេងៗ

**ប្រធានបទទី១៖** ការឆ្លើយតបប្រកបដោយចីរភាពឈានទៅបញ្ចប់អេដស៍ ជាគ្រោះគំរាមដល់សុខភាពសាធារណៈត្រឹមឆ្នាំ២០២៥

១-រចនាសម្ពន្ធនៃការឆ្លើយតប ក្នុងនោះដែរឯកឧត្តមអគ្គលេខាធិការ បានលើកឡើងពីច្បាប់ និងអនុក្រឹត្យមកបង្ហាញដូចជា ព្រះរាជក្រមលេខ នស/រកម/០៧០៣/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើប្រាស់ស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងជំពូកទី១ និងជំពូកទី៩ និងអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលាឆ្នាំ២០០៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងអង្គការលេខនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

២-បច្ចុប្បន្នភាពស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅ ប្រទេសកម្ពុជា អាស៊ីប៉ាស៊ីហ្វិក និងសកលលោកក្នុងឆ្នាំ២០១៩មាន៖

-អ្នករស់នៅជាមួយមេរោគអេដស៍នៅប្រទេសកម្ពុជាមានចំនួន ៧៣,០០០នាក់ នៅអាស៊ីប៉ាស៊ីហ្វិកមានចំនួន៥.៨លាននាក់ និងនៅសកលលោកមានចំនួន៣៨លាននាក់។

-អ្នកឆ្លងមេរោគអេដស៍ថ្មីនៅប្រទេសកម្ពុជា មានចំនួន៧៨០នាក់ នៅអាស៊ីប៉ាស៊ីហ្វិកមានចំនួន ៣០០,០០០នាក់ នៅសកលលោកមានចំនួន១.៧លាននាក់។

-អ្នកឆ្លងមេរោគអេដស៍ដែលបានស្លាប់នៅប្រទេសកម្ពុជាមានចំនួន១,៣០០នាក់ នៅអាស៊ីប៉ាស៊ីហ្វិកមានចំនួន១៦០,០០០នាក់ នៅសកលលោកមានចំនួន៦៩០,០០០នាក់។

-អ្នកមកទទួលសេវាព្យាបាលមេរោគអេដស៍នៅកម្ពុជាមានចំនួន ៦១,១៩៣នាក់ នៅអាស៊ីប៉ាស៊ីហ្វិកមានចំនួន ៣.៥លាននាក់ នៅសកលលោកមានចំនួន២៥.៤លាននាក់។

៣-យុទ្ធសាស្ត្រឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍មានៈ

-ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣ ដែលជាផែនទីចង្អុលផ្លូវតែមួយគត់សម្រាប់ការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាដែលដឹកនាំអនុវត្តដោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយផ្អែកលើសសរស្តម្ភទាំងបីរួមមាន ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ ភាពជាដៃគូការវិនិយោគ ដើម្បីធានាភាពជោគជ័យ និងចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

-វិធានការទាំងប្រាំមួយ ដូចមានចែងក្នុងសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

៤-អនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី-ខេត្ត។

៥-ប្រកាសអន្តរក្រសួង លេខ១៨២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីអំពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី-ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។

៦-ប្រកាសអន្តរក្រសួង លេខ១៥២ សនក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាល រាជធានី ខេត្ត។

**ប្រធានបទទី ២៖** ទំនាក់ទំនងអនឡាញ (Communication on line)

យុទ្ធនាការថ្នាក់ជាតិផ្សព្វផ្សាយអប់រំអំពីការបង្ការ និងទទួលសេវាមេរោគអេដស៍

១-សមិទ្ធផលនៃការផ្សព្វផ្សាយរយៈពេល៣ខែ មានសកម្មភាពដូចជាៈ រឿងភាគខ្លីៗ, រូបភាពភ្ជាប់ជាមួយសារអប់រំ។ តាមរយៈរឿងភាគខ្លីៗ យើងសង្កេតឃើញថា មានចំនួនអ្នកមើល ៦៦៩,៨០០នាក់ និងចំនួនអ្នកមើលតាមការផ្សព្វផ្សាយយ៉ាងហោចណាស់ មួយលើកមានចំនួន ៥.០៨លាននាក់

(ច្រើនជាងគេនៅភ្នំពេញ បាត់ដំបង សៀមរាប ស្វាយរៀង កណ្ដាល)។ រីឯការផ្សព្វផ្សាយតាមរយៈកម្មវិធី "គោះគេស្ត" ដែលមានអ្នកបានឃើញមានចំនួន ៩៦៣,០០០នាក់ អ្នកចូលទៅមើលគេហទំព័រចំនួន ៤,២០០នាក់ អ្នកចូលកក់សេវាចំនួន ៩២នាក់ អ្នកមកដល់គ្លីនិកចំនួន ៤៥នាក់(៤២នាក់បានធ្វើតេស្តរកមេរោគអេដស៍ និងកាមរោគ ឃើញថាចំនួនតេស្តវិជ្ជមានដោយមេរោគអេដស៍ ៥នាក់(MSM) និងចំនួនតេស្តវិជ្ជមានដោយកាមរោគមាន៦នាក់(MSM)និងផ្ដល់សេវា PrEP មានចំនួន១នាក់។ ចំពោះអ្នកឆាតសួរអំពីការធ្វើតេស្ត PEP PrEP និងព្យាបាល មានចំនួន១៨១នាក់។ មិនតែប៉ុណ្ណោះមានសេវាដែលអតិថិជនអាចចូលទៅកក់បានដូចជា៖

-ធ្វើតេស្តរកមេរោគអេដស៍

-ធ្វើតេស្តរកកាមរោគ និងព្យាបាលកាមរោគ

-PEP PrEP

-ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

-ការគ្រប់គ្រងជំងឺសិរមាន់នៅប្រដាប់ភេទ

-វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទB និងមហារីកស្បូន

-ព្យាលបាលដោយប្រើអ័រម៉ូន

**៣-មតិយោបល់៖**

តំណាងក្រសួងធម្មការ និងសាសនា បានស្នើសុំឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ធ្វើលិខិតគតិយុត្តិ ទៅតាមក្រសួង ស្ថាប័ននីមួយៗ ដែលជាសមាជិកលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ភ្ជាប់ជាឯកសារយោង នៅពេលដែលធ្វើគម្រោងស្នើសុំថវិកា ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចុងបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានសំណូមពរដល់ក្រសួង ស្ថាប័ន ដែលជាសមាជិក សមាជិកាជួយផ្ដល់ និងចែករំលែកបទពិសោធន៍ ឯកសារ បទបង្ហាញផ្សេងៗ របស់សាមីស្ថាប័នអង្គភាពពាក់ព័ន្ធ ព្រមទាំងចូលរួមជំរុញការផ្សព្វផ្សាយការឆ្លើយតបជាពហុវិស័យដើម្បីសម្រេចគោលដៅបញ្ចប់ការចម្លងមេរោគអេដស៍ត្រឹមឆ្នាំ២០២៥ និងទិសដៅ ៩៥ ៩៥ ៩៥ ព្រមទាំងគោលនយោបាយសូន្យ-បី (គ្មានការចម្លងថ្មី គ្មានការស្លាប់ គ្មានការរើសអើង)។

អង្គប្រជុំក៏បានឯកភាព និងកំណត់ការប្រជុំលើកក្រោយនៅថ្ងៃសុក្រ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី២៨ខែសីហា ឆ្នាំ២០២០។

ថ្ងៃសុក្រ១១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

| បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់ | បានពិនិត្យត្រឹមត្រូវ | **អ្នកធ្វើរបាយការណ៍** |
| --- | --- | --- |
| **អគ្គលេខាធិការ** | **ប្រធាននាយកដ្ឋាន ទាក់ទង និងចលនាប្រភពធនធាន** | |
| | | **ស៊ុំ ផល្លា** |